ក្រសួងអភិវឌ្ឍន៍ជនបទ
ចូល
លេខៈ ១៤៨៧ ក.អ.ជ
ថ្ងៃទី០៨.១១.១៤ ម៉ោង ៤:៤០
បញ្ជូន.....................

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧១៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការបង្កើតគណៈកម្មាធិការផលិតភាពកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបានបង្កើត “**គណៈកម្មាធិការផលិតភាពកម្ពុជា**” សរសេរជាអក្សរកាត់ថា “គ.ផ.ក.” ដែលជាគណៈកម្មាធិការផ្នែកគោលនយោបាយសេដ្ឋកិច្ចពលកម្ម ផលិតភាពពលកម្ម និងភាពប្រកួតប្រជែង នៅក្រោមគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (គ.ស.ហ.)។

## ជំពូកទី២
## សមាសភាពនិងរចនាសម្ព័ន្ធ

**មាត្រា២.-**

គ.ផ.ក. មានសមាសភាពដូចតទៅ៖

| | |
|---|---|
| ១-ឧបនាយករដ្ឋមន្ត្រី និងជាប្រធាន គ.ស.ហ. | ប្រធាន |
| ២-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធានប្រចាំការ |
| ៣-រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម | អនុប្រធាន |
| ៤-រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៥-ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | អនុប្រធាន |
| ៦-រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៧-អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា | សមាជិក |
| ៨-រដ្ឋមន្ត្រីក្រសួងផែនការ | សមាជិក |
| ៩-រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១០-រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ១១-រដ្ឋមន្ត្រីក្រសួងបរិស្ថាន | សមាជិក |
| ១២-រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ១៣-រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ១៤-រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | សមាជិក |
| ១៥-រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៦-រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល | សមាជិក |
| ១៧-រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៨-អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៩-រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ០១ រូប | សមាជិក |
| ២០-រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ០១ រូប | សមាជិក |
| ២១-តំណាងប្រតិបត្តិករសេដ្ឋកិច្ច ០២ រូប | សមាជិក |
| ២២-តំណាងពីមជ្ឈដ្ឋានសិក្សាស្រាវជ្រាវ ០២ រូប | សមាជិក។ |

សមាសភាពជាក់ស្តែងនៃ គ.ផ.គ. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៣.-**

គ.ផ.គ. មានលេខាធិការដ្ឋានមួយជាសេនាធិការក្នុងកិច្ចការរដ្ឋបាល និងការងារបច្ចេកទេសសិក្សាស្រាវជ្រាវ ដែលត្រូវបង្កើតឡើងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលតាមសំណើរបស់ប្រធាន គ.ផ.គ. សម្រាប់គាំទ្រកិច្ចដំណើរការការងាររបស់ខ្លួន។ ប្រធាន អនុប្រធាន និងសមាជិកនៃលេខាធិការដ្ឋាន គ.ផ.គ. ត្រូវមានគុណវុឌ្ឍិនិងសមត្ថភាពជំនាញ ព្រមទាំងមានបទពិសោធន៍ខ្ពស់ខាងផ្នែកសេដ្ឋកិច្ចពលកម្ម និងផលិតភាព។ សមាសភាពលេខាធិការដ្ឋាន គ.ផ.គ. ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលតាមសំណើរបស់ប្រធាន គ.ផ.គ.។

## ជំពូកទី៣

## តួនាទីនិងភារកិច្ច

**មាត្រា៤.-**

គ.ផ.គ. មានតួនាទីនិងភារកិច្ចដូចតទៅ÷

- សិក្សា និងវិភាគអំពីសេដ្ឋកិច្ចពលកម្ម ផលិតភាពពលកម្ម និងភាពប្រកួតប្រជែង ដើម្បីផ្តល់អនុសាសន៍ និងធាតុចូលជូនប្រមុខរាជរដ្ឋាភិបាល សម្រាប់ការរៀបចំក្របខ័ណ្ឌយុទ្ធសាស្ត្រ ក្របខ័ណ្ឌគោលនយោបាយ និងគោលនយោបាយសេដ្ឋកិច្ចពលកម្ម ផលិតភាពពលកម្ម ភាពប្រកួតប្រជែង ការអភិវឌ្ឍភាពជាដៃគូ

រវាងផ្នែកសាធារណៈ ផ្នែកសាជីវកម្ម និងផ្នែកផ្សារពលកម្ម ដោយត្រូវធានាឱ្យបាននូវសង្គតិភាពនិងភាពស៊ីសង្វាក់គ្នាជាមួយគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ និងកម្មវិធីនានារបស់រាជរដ្ឋាភិបាល ពិសេសជាមួយគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម

- ពិនិត្យ និងវាយតម្លៃអំពីសង្គតិភាព និងភាពគ្រប់ជ្រុងជ្រោយ ព្រមទាំងប្រសិទ្ធភាពនៃការអនុវត្ត យុទ្ធសាស្ត្រ គោលនយោបាយ និងកម្មវិធីនានារបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងសេដ្ឋកិច្ចពលកម្ម ផលិតភាពពលកម្ម និងភាពប្រកួតប្រជែង និងលើកអនុសាសន៍ជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីដាក់ចេញនូវវិធានការកែលម្អ
- ធ្វើកិច្ចសហការជាមួយតួអង្គពាក់ព័ន្ធ រួមមាន វិស័យឯកជន សហជីពកម្មករ និងដៃគូអភិវឌ្ឍសហប្រតិបត្តិការផ្លូវការ ដើម្បីជំរុញ លើកកម្ពស់វប្បធម៌ផលិតភាពជាតិ និងភាពប្រកួតប្រជែង សម្រាប់ការអភិវឌ្ឍជាតិ ព្រមទាំងបង្កើនភាពប្រកួតប្រជែងនៃផលិតផល និងពលករកម្ពុជា នៅក្នុងទីផ្សារតំបន់ និងពិភពលោក ដែលនាំឱ្យមានកំណើនប្រាក់ចំណូលពិតរបស់កម្មករ និយោជិតកម្ពុជា
- សិក្សា និងផ្តល់អនុសាសន៍ជូនប្រមុខរាជរដ្ឋាភិបាល អំពីគោលនយោបាយ និងក្របខ័ណ្ឌសម្រាប់កំណត់ប្រាក់ឈ្នួលអប្បបរមា សម្រាប់កម្មករនិយោជិតលើគ្រប់វិស័យ ក្នុងគោលដៅធានាបាននូវជីវភាពសមរម្យជូនកម្មករ និយោជិតផង និងដោយធានាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការលើកកម្ពស់ផលិតភាពពលកម្ម ភាពប្រកួតប្រជែង និងភាពទាក់ទាញនៃសេដ្ឋកិច្ចកម្ពុជាសម្រាប់ការវិនិយោគផង
- បំពេញការងារផ្សេងទៀត តាមការបញ្ជារបស់ប្រធាន **គ.ស.ជ.** ឬរបស់ប្រមុខរាជរដ្ឋាភិបាល។

## ជំពូកទី៤

## ដំណើរការការងារ

**មាត្រា៥.-**

តាមការអញ្ជើញរបស់ប្រធាន អនុប្រធាន និងសមាជិក **គ.ផ.ត.** ត្រូវចូលរួមប្រជុំ ឬចាត់តាំងតំណាងដែលមានសិទ្ធិសម្រេចជំនួស ដើម្បីចូលរួមប្រជុំ ក្នុងករណីអវត្តមាន ឬមានធុរៈ។

ក្នុងករណីប្រធានអវត្តមាន **គ.ផ.ត.** អាចដំណើរការប្រជុំ ក្រោមអធិបតីភាពរបស់អនុប្រធាន ឬរបស់តំណាងតាមការប្រគល់សិទ្ធិរបស់ប្រធាន។

**គ.ផ.ត.** ប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅក្នុងការបំពេញការងារ។

**មាត្រា៦.-**

**គ.ផ.ត.** មានសិទ្ធិអញ្ជើញថ្នាក់ដឹកនាំ មន្ត្រីជាន់ខ្ពស់នៃក្រសួង-ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ឬឥស្សរជន ដែលមានបទពិសោធន៍ និងសមត្ថភាពខ្ពស់ ចូលរួមការងារ ឬផ្តល់យោបល់ក្នុងកិច្ចប្រជុំរបស់ខ្លួនបាន។

**គ.ផ.ត.** មានសិទ្ធិអញ្ជើញតំណាងដៃគូអភិវឌ្ឍន៍ តំណាងវិស័យឯកជន តំណាងសហជីព និងតំណាងសង្គមស៊ីវិល ចូលរួមប្រជុំក្នុងឋានៈជាសមាជិក ឬអ្នកសង្កេតការណ៍ តាមការចាំបាច់។

គ្រប់ក្រសួង និងស្ថាប័នដែលមានការពាក់ព័ន្ធទាំងអស់របស់រាជរដ្ឋាភិបាល មានភារកិច្ចផ្តល់ឯកសារ ព័ត៌មាន និងកិច្ចសហការចាំបាច់នានាជូនដល់ **គ.ផ.ត.**។

**មាត្រា៧.-**

លេខាធិការដ្ឋាន **គ.ផ.ត.** មានប្រភពធនធានផ្គត់ផ្គង់ដោយថវិកាជាតិ ជាកញ្ចប់ថវិកាដោយឡែក នៅក្នុងក្របខ័ណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានសិទ្ធិទទួល និងគ្រប់គ្រងមូលនិធិ ដែលបានមកពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការបរទេស និងពីប្រភពផ្សេងទៀត សម្រាប់ចំណាយលើការសិក្សាស្រាវជ្រាវ សេវារដ្ឋបាល និងសម្រាប់បម្រើសេចក្តីត្រូវការ ក្នុងការផ្គត់ផ្គង់សម្ភារៈ បរិក្ខារ និងការឧបត្ថម្ភផ្សេងៗ តាមការចាំបាច់ ក្នុង

គោលដៅធានាប្រសិទ្ធភាពក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា៨.-**

ត្រូវបាននិរាករ ដូចតទៅ÷

- សេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល លេខ ០៤ សសរ ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៤ ស្ដីពីការបង្កើតគណៈកម្មការសិក្សាស្រាវជ្រាវប្រាក់ឈ្នួលអប្បបរមា សម្រាប់កម្មករនិយោជិត ផ្នែកវាយនភ័ណ្ឌ កាត់ដេរសំលៀកបំពាក់ និងផលិតស្បែកជើង
- សេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល លេខ ៣៣ សសរ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ ស្ដីពីការតែងតាំងសមាសភាពគណៈកម្មការសិក្សាស្រាវជ្រាវប្រាក់ឈ្នួលអប្បបរមា សម្រាប់កម្មករ និយោជិត ផ្នែកវាយនភ័ណ្ឌ កាត់ដេរសំលៀកបំពាក់ និងផលិតស្បែកជើង។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៩.-**

ប្រធាន គ.ស.ហ. រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ៣ ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាប

ជូនសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គាត ឈន់**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ